# ផលប៉ះពាល់នៃកិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចថ្នាក់តំបន់ទូលំទូលាយ មកលើកសិករ និងស្បៀងអាហារ

GRAIN ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៧

កិច្ចព្រមព្រៀងស្តីពីភាពជាដៃគូសេដ្ឋកិច្ចថ្នាក់តំបន់ទូលំទូលាយ(RCEP) គឺជាកិច្ចព្រមព្រៀងពាណិជ្ជកម្មប្រចាំតំបន់ដ៏ធំមួយដែលត្រូវបានចរចាក្នុងចំណោម១៦ប្រទេស នៅទូទាំងអាស៊ីប៉ាស៊ីហ្វិក។ ប្រសិនបើត្រូវអនុម័ត RCEPនឹងគ្របដណ្តប់លើប្រជាជនចំនួនពាក់កណ្តាលនៃពិភពលោក រួមទាំងកសិកម្មខ្នាតតូចលក្ខណៈគ្រួសារចំនួន ៥០០ លានដែលផលិតស្បៀងអាហារ៨0% សម្រាប់តំបន់។ RCEP ត្រូវគេរំពឹងថានឹងបង្កើតនូវសិទ្ធិដ៏មានឥទ្ធិពលថ្មីមួយ និងឱកាសសម្រាប់ធ្វើជំនួញរកប្រាក់ចំណេញរបស់ក្រុមហ៊ុនសាជីវកម្មទៅលើស្បៀងអាហារ និងកសិកម្មនៅក្រោមរូបភាពជាការជំរុញពាណិជ្ជកម្ម និងការវិនិយោគ។ ប្រទេសនៅក្នុងកិច្ចព្រមព្រៀងRCEP ជាច្រើនក៏ជាភាគីនៅក្នុងកិច្ចព្រមព្រៀងភាពជាដៃគូអន្តរប៉ាស៊ីហ្វិក (TPP)ជាកិច្ចព្រមព្រៀងថ្នាក់តំបន់ដ៏ធំមួយផ្សេងទៀតដែលដាក់ចេញនូវគោលការណ៍គាំទ្រជំនួញខ្នាតធំ មិនធ្លាប់មាននៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មនានាមកទល់ពេលនេះ។ ខណៈដែលជោគវាសនារបស់TPP នៅមិនទាន់ប្រាកដប្រជានៅឡើយ កិច្ចព្រមព្រៀងទាំងពីរនេះអាចនឹងកើតតំនាលគ្នា ហើយមានការលំបាកក្នុងការដាក់បញ្ចូលគ្នាលើចំណុចជាច្រើន។ តើនេះនឹងមានន័យដូចម្តេចសម្រាប់កសិករ និងស្បៀងអាហារនៅក្នុងតំបន់?

## ១. ដីធ្លីនឹងត្រូវដណ្តើមយក

ប្រទេសភាគច្រើននៅក្នុងRCEP មិនអនុញ្ញាតឲ្យជនបរទេសទិញដីកសិកម្មនោះទេ។ ជំនួសមកវិញ វិនិយោគិនបរទេសអាចជួល ទទួលបានសម្បទាន និងការលើកលែងលើបទបញ្ញត្តិផ្សេងៗ។ ភាគហ៊ុននៅពីក្រោយនេះមានកំណើនខ្ពស់ដោយសារមូលនិធិសម្រាប់វិនិយោគ និងក្រុមហ៊ុនជាច្រើនបានសម្រុកទិញយកដីកសិកម្មទុកជាប្រភពចំណូលថ្មីមួយកាលពីឆ្នាំមុន។ គ្រាន់តែនៅក្នុងប្រទេសសមាជិកRCEPទាំងមូល ដីកសិកម្មចំនួន ៩,៦លានហិចតាត្រូវបានកាន់កាប់ដោយក្រុមហ៊ុនបរទេសតាំងពីឆ្នាំ២០០៨មក។ ភាពជាម្ចាស់នោះ ផ្តល់ឲ្យក្រុមហ៊ុនសាជីវកម្មនូវអំណាចគ្រប់គ្រង

ច្រើនជាងការគោរពសិទ្ធិ ប៉ុន្តែវាក៏ធ្វើឲ្យតម្លៃដីធ្លីកើនឡើង និងមានហានិភ័យមួយគឺបណ្តេញកសិករខ្នាតតូចចេញពីដី។

ជំពូកចំនួនពីរនៅក្នុងRCEP អាចមានផលប៉ះពាល់ចម្បងមួយទៅលើលទ្ធភាពទទួលបានដីធ្លី។ យោងទៅលើសេចក្តីព្រាងដែលបានបែកធ្លាយ ជំពូកស្តីពីការវិនិយោគបានស្នើនូវច្បាប់មួយដែលរដ្ឋាភិបាលនីមួយៗត្រូវយកចិត្តទុកដាក់លើវិនិយោគិនពីប្រទេសនៅក្នុងRCEPដទៃស្មើគ្នានឹងវិនិយោគិនក្នុងស្រុក (ការយកចិត្តទុកដាក់កម្រិតជាតិ)។ នោះមានន័យថា ពួកគេគួរមានសិទ្ធិដូចគ្នាក្នុងការទិញដីកសិកម្មដូចវិនិយោគិនក្នុងស្រុក ប្រសិនបើរដ្ឋាភិបាលមិនដាក់ចេញនូវការលើកលែងពិសេសចំពោះករណីនេះ។ ជំពូកព្រាងនោះក៏មានស្នើនូវអនុប្រយោគ "បិទផ្លូវ" ឬ "ខ្ទាស់"ដែល ប្រសិនបើអនុម័ត វាមានន័យថារដ្ឋាភិបាលត្រូវតែបិទនូវការធ្វើសេរីភាវូបនីយកម្មត្រឹមកម្រិតបច្ចុប្បន្ន ហើយប្រសិនបើពួកគេបើកសេរីច្រើនជាងអ្វីដែលគេប្តេជ្ញានៅក្នុងRCEP គេមិនអាចបកទៅកម្រិតដែលកំណត់ដោយRCEPនោះទេ។ រីឯជំពូកព្រាងស្តីពីសេវាកម្មវិញ ក៏បានស្នើថាអ្នកផ្គត់ផ្គង់សេវាកម្មបរទេសគួរត្រូវបានយកចិត្តទុកដាក់ស្មើនឹងក្រុមហ៊ុនក្នុងស្រុកដែរ(ការយកចិត្តទុកដាក់កម្រិតជាតិ)។ នេះ រួមបញ្ចូលទាំងលទ្ធភាពក្នុងការកាន់កាប់ដីកសិកម្មសម្រាប់គោលបំណងទាក់ទងនឹងការផ្តល់សេវាកម្មណាមួយ។ ជាថ្មីម្តងទៀត ប្រទេសទាំងឡាយអាចនឹងត្រូវបង្ខំឲ្យមានករណីលើកលែងសម្រាប់ដីកសិកម្ម ប៉ុន្តែករណីលើកលែងបែបនោះនឹងត្រូវឆ្លងកាត់ការចរចា ហើយត្រូវមានការព្រមព្រៀងពីគ្រប់ភាគីទាំងអស់។

ប្រសិនបើរដ្ឋាភិបាលមិនគិតគូរជាមុនលើបញ្ញត្តិដីកសិកម្មទាំងនេះទេ RCEPអាចបង្កឲ្យមានការដណ្តើមយកដីកាន់តែអាក្រក់ទៅៗនៅក្នុងតំបន់ និងរារាំងដល់ដំណើរការធ្វើកំណែទម្រង់កសិកម្មដែលកំពុងអនុវត្តក្នុងប្រទេសមួយចំនួននាពេលបច្ចុប្បន្ន។ សព្វថ្ងៃនេះ កសិករដែលទាមទារសិទ្ធិដីធ្លីរបស់ពួកគេ កំពុងក្លាយជាគោលដៅនៃការរំលោភសិទ្ធិមនុស្ស ឧក្រិដ្ឋកម្ម ការឃុំឃាំងនិងការលួចធ្វើឃាត។ ដោយហេតុផលនេះ ទើបមានភាពភ័យខ្លាចដ៏ខ្លាំងមួយដែលថាប្រសិនបើRCEPត្រូវបានអនុម័តមែននោះ វានឹងបង្កើននូវឃោឃៅនីយកម្មនៅតាមសហគមន៍ជនបទ។

## ២. គ្រាប់ពូជនឹងត្រូវធ្វើឯកជននីយកម្ម ហើយពូជ GMO (ពូជបង្កាត់ហែ្សន)នឹងកើនឡើង

ជាទៀងទាត់ កសិករទុកពូជពីការប្រមូលផលសម្រាប់ការដាំដុះថ្មី។ ក្រុមហ៊ុនផលិតគ្រាប់ពូជ និងផលិតផលគីមីសម្រាប់កសិកម្មធំៗដូចជាក្រុមហ៊ុន ម៉ុនសានតូ (Mosanto) និង បាយ័រ (Bayer) ចង់បញ្ចប់ការអនុវត្តបែបនេះ ហើយបង្ខំកសិករឲ្យទិញពូជរាល់រដូវ ដូច្នេះពួកគេអាចបង្កើនការលក់កាន់តែច្រើន។ ពួកគេធ្វើបែបនេះដោយបញ្ចុះបញ្ចូលរដ្ឋាភិបាលឲ្យពង្រីកច្បាប់កម្មសិទ្ធិបញ្ញាបន្ថែមទៅលើរុក្ខជាតិ និងសត្វ។ ឧស្សាហាកម្មគ្រាប់ពូជសកលនេះ កំពុងមានការគ្រប់គ្រងយ៉ាងខ្លាំងដោយក្រុមហ៊ុនចំនួនបី ដែលតំណាងឲ្យជាង ៦០%នៃការធ្វើពាណិជ្ជកម្មគ្រាប់ពូជក្នុងពិភពលោក។ បច្ចុប្បន្ន ក្រុមហ៊ុន ឆឹមឆាយណា (ChemChina) កំពុងដំណើរការទិញយកក្រុមហ៊ុន ស៊ីជេនតា (Syngenta) ដែលជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនគ្រាប់ពូជធំទាំងបីនៅក្នុងពិភពលោក។ នេះមានន័យថា ប្រទេសចិនមានចំណាប់អារម្មណ៍ថ្មីមួយក្នុងការពង្រឹងច្បាប់គ្រាប់ពូជនៅក្រោមកិច្ចព្រមព្រៀង RCEP។

សេចក្តីព្រាងដែលបែកធ្លាយនៅជំពូកស្តីពីកម្មសិទ្ធិបញ្ញានៅក្នុងRCEP បង្ហាញថា ប្រទេសនានាដូចជាប្រទេសជប៉ុន និងកូរ៉េខាងត្បូងកំពុងជំរុញរដ្ឋភាគីនៅក្នុងRCEP ទាំងអស់ឲ្យអនុម័ត "UPOV 1991" ដែលជាប្រព័ន្ធចុះប្រកាសនីយប័ត្រតក្កកម្ម (ប៉ាតង់)មួយប្រភេទទៅលើគ្រាប់ពូជ។ នៅក្រោម "UPOV 1991" ជាទូទៅ កសិករមិនត្រូវបានអនុញ្ញាតឲ្យទុកប្រភេទពូជដែលត្រូវបានការពារនោះទេ។ ខណៈដែលអាចមានករណីលើកលែងតិចតួច កសិករត្រូវបង់ថ្លៃអាជ្ញាប័ណ្ណលើគ្រាប់ពូជដែលត្រូវទុកសម្រាប់ដាំដុះ។ ដោយអាស្រ័យតាមប្រទេស និងប្រភេទដំណាំ ការបង់ថ្លៃបន្ថែមលើអាជ្ញាប័ណ្ណអាចមានរហូតដល់១០ ទៅ៥០%ពីលើតម្លៃគ្រាប់ពូជដាក់លក់ធម្មតា ដែលនេះមានតម្លៃថ្លៃជាងគ្រាប់ពូជរបស់កសិករទៅទៀត។ ក្រុមអង្គការសង្គមស៊ីវិល ប៉ាន់ប្រមាណថា UPOV 1991 នឹងបង្កើនតម្លៃគ្រាប់ពូជក្នុងស្រុកពី២០០ទៅ៦០០% នៅក្នុងប្រទេសថៃ និងដល់ ៥០០%នៅក្នុងប្រទេសហ្វីលីពីន។

វាអាចនឹងកាន់តែអាក្រក់ប្រសិនបើRCEP បន្តការចរចាកាន់តែដូចអ្វីដែលមាននៅក្នុងកិច្ចព្រមព្រៀង TPPដែលភាគីរដ្ឋចំនួន៩នៅក្នុងRCEP បានព្រមព្រៀងរួចមកហើយ។ TPPទាមទាររដ្ឋភាគីអនុញ្ញាតឲ្យដាក់ប៉ាតង់លើការបង្កើតថ្មីដែល"ទាញចេញពីរុក្ខជាតិ" សំដៅដល់ពពួក រុក្ខជាតិបំលែងហែ្សន

(GMOs)។ បច្ចុប្បន្ន ពូជGMOsស្ថិតក្នុងប្រភេទមិនស្របច្បាប់នៅក្នុងប្រទេសសមាជិកRCEPទាំងអស់ លើកលែងប្រទេសអូស្ត្រាលី ឥណ្ឌា មីយ៉ាន់ម៉ា និងហ្វីលីពីន បូករួមខេត្តមួយចំនួននៅប្រទេសចិន និងវៀតណាមផងដែរ។ ខណៈដែលRCEP ទំនងជាមានជំពូកមួយដែលចង់ដាក់បទដ្ឋាន (ស្តង់ដារ)លើសុវត្ថិភាពចំណីអាហារ ពួកយើងមិនទាន់បានឃើញសេចក្តីព្រាងណាមួយនៅឡើយ ហើយមិនដឹងថាវានឹងដាក់បញ្ញត្តិលើពូជGMOsដោយរបៀបណានោះទេ។ ការវិវត្តទាំងអស់នេះមិនត្រឹមតែបង្កើនតម្លៃគ្រាប់ពូជប៉ុណ្ណោះទេ វាថែមទាំងនាំទៅរកការបាត់បង់ជីវៈចម្រុះ ការគ្រប់គ្រងពីក្រុមហ៊ុនសាជីវកម្មកាន់តែខ្លាំងជាងមុន និងលទ្ធភាពក្នុងការបន្ទាបស្តង់ដារលើទិន្នផលដែលមានហានិភ័យខ្ពស់ដូចជាGMOs ជាដើម។

## ៣. អ្នកផលិតទឹកដោះគោ និងកសិករខ្នាតតូចដទៃទៀតនឹងលែងប្រកបរបរបាន

ប្រទេសឥណ្ឌា មានកសិករខ្នាតតូច ១០០ លាននាក់ ដែលភាគច្រើនប្រើគោក្របីនៅឡើយ។ រហូតមកទល់បច្ចុប្បន្ន ពួកគេគឺជាឆ្អឹងខ្នងនៃវិស័យផលិតផលទឹកដោះគោរបស់ឥណ្ឌា ប៉ុន្តែស្ថានភាពនោះកំពុងមានការផ្លាស់ប្តូរហើយ។ តម្លៃផលិតកម្មកំពុងកើនឡើង ខណៈដែលតម្លៃផលិតផលរបស់កសិករធ្លាក់ចុះ ធ្វើឲ្យកសិករខ្នាតតូចជាច្រើនជួបការលំបាក។

RCEP នឹងធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ឡើង។ ដោយមិនពេញចិត្តជាមួយនឹងបរាជ័យរបស់ប្រទេសញូវហ្សេលែនក្នុងការសម្រេចនូវកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយឥណ្ឌា ក្រុមហ៊ុនយក្សខាងផលិតផលទឹកដោះគោរបស់ញូវហ្សេលែនឈ្មោះ ហ្វុនធីរ៉ា (Fonterra) ហើយក៏ជាអ្នកនាំចេញផលិតផលទឹកដោះគោធំជាងគេនៅលើពិភពលោក កំពុងមើលឃើញRCEP ជាវិធីមួយក្នុងការចូលទៅក្នុងទីផ្សារផលិតផលទឹកដោះគោដ៏ធំរបស់ឥណ្ឌា។ វាបានប្រកាសដោយចំហថាRCEP នឹងផ្តល់អានុភាពខ្លាំងដល់ក្រុមហ៊ុនក្នុងការបើកទីផ្សារសំខាន់ ដែលកំពុងស្ថិតក្នុងការការពារដូចជាទីផ្សារឥណ្ឌា ដែលគេនឹងប្រកួតប្រជែងដោយផ្ទាល់ជាមួយសហករណ៍ផលិតផលទឹកដោះគោរបស់ឥណ្ឌាឈ្មោះ អាមុល។ ជាលទ្ធផល ប្រជាជនភាគច្រើនភ័យខ្លាចថា កសិករឥណ្ឌាដែលផលិតផលិតផលទឹកដោះគោនឹងត្រូវ ធ្វើការឲ្យក្រុមហ៊ុនហ្វុនធីរ៉ាឬលែងប្រកបរបរនេះបាន។ ពួកគេនឹងមិនអាចប្រកួតប្រជែងបានឡើយ។ ក្តីបារម្ភស្រដៀងគ្នានេះក៏មានសម្រាប់កសិករផលិតផលិតផលទឹក

ដោះគោនៅ ប្រទេសវៀតណាមដែរ ដែលក្រុមហ៊ុនហ្វុនធីវ៉ាកំពុងវិនិយោគយ៉ាងខ្លាំងដើម្បីបង្កើននូវវត្តមានរបស់ខ្លួន។

ស្របពេលជាមួយគ្នានេះដែរ សមាជិកRCEPមួយចំនួនដូចជាប្រទេសជប៉ុន និងអូស្ត្រាលីមិនត្រឹមតែឧបត្ថម្ភធនយ៉ាងសម្បើមដល់កសិកររបស់ពួកគេប៉ុណ្ណោះទេ ពួកគេថែមទាំងមានស្តង់ដារសុវត្ថិភាពចំណីអាហារមិនអាចប្រកួតប្រជែងបានសម្រាប់ផលិតកម្មចំណីអាហារ និងប្រព័ន្ធកែច្នៃអាហារខ្នាតតូច ដែលមានប្រៀបជាងគេនៅក្នុងប្រទេសសមាជិក RCEP។ ការណ៍នេះនឹងនាំឲ្យមានកំនើនវិនិយោគលើសង្វាក់ផលិតកម្មអាហារដោយផ្ទាល់ជាទ្រង់ទ្រាយធំ ដែលមានទិសដៅសម្រាប់នាំចេញទៅកាន់ទីផ្សារមានតម្លៃខ្ពស់ដូចអ្វីដែលកំពុងកើតមាននៅក្នុងប្រទេសឥណ្ឌារួចទៅហើយ។ គម្រោងទាំងនេះ បញ្ចូលសង្វាក់ផ្គត់ផ្គង់ដោយផ្ទាល់ពី កសិដ្ឋានតាមបច្ចេកវិទ្យាទំនើប ដែលផាត់ចេញ ឬអាចលុបបំបាត់អ្នកផលិតខ្នាតតូច និងរបរកែច្នៃអាហារលក្ខណៈគ្រួសារដែលជាប្រភពទ្រទ្រង់សហគមន៍នៅជនបទ និងជាយក្រុងនៅទូទាំងអាស៊ី។

## ៤.ការប្រើប្រាស់ជី និងថ្នាំសម្លាប់សត្វល្អិតនឹងកើនឡើង

ការលក់ជីនិងថ្នាំសម្លាប់សត្វល្អិត ត្រូវបានរំពឹងថានឹងកើនឡើងខ្ពស់នៅតំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងរយៈពេលពីរបីឆ្នាំខាងមុខ ក្នុងទំហំទឹកប្រាក់ពី ១០០ពាន់លានដុល្លារអាមេរិក ទៅដល់ ១២០ ពាន់លានដុល្លារក្នុងមួយឆ្នាំត្រឹមឆ្នាំ ២០២១។ ការប្រើប្រាស់សារធាតុគីមីក្នុងកសិកម្ម មានអត្រាខ្ពស់ជាងគេបំផុតក្នុងប្រទេសចិន និងកំពុងកើនឡើងយ៉ាងគំហុកនៅប្រទេសឥណ្ឌា ខណៈដែលការនាំចេញផលិតផលពីអនុតំបន់ទន្លេមេគង្គក៏កំពុងកើនឡើងដែរ។ ការកាន់កាប់ក្រុមហ៊ុន ស៊ីជេនតា ដោយចិន ដែលជាក្រុមហ៊ុនផលិតផលគិមីសម្រាប់កសិកម្ម កំពូលនៅលើពិភពលោក គ្របដណ្តប់ទីផ្សារថ្នាំសម្លាប់សត្វល្អិតសកលច្រើនជាង ២០% បានធ្វើឲ្យប្រទេសចិនដើរតួនាទីសំខាន់នៅក្នុងកិច្ចព្រមព្រៀង RCEP។

ទីក្រុងប៉េកាំង នឹងចង់បាននូវ"ការបើកទីផ្សារ" កម្រិតខ្ពស់ ដែលកំពុងស្ថិតក្នុងការចរចាក្រោមជំពូកស្តីពីពាណិជ្ជកម្មទំនិញនៅក្នុង RCEP ដើម្បីក្តោបក្តាប់យកក្នុងតួនាទីថ្មីរបស់ខ្លួន។ នៅខែមករា ឆ្នាំ

២០១៧ ប្រទេសចិនបានប្រកាសរួចហើយថា ខ្លួននឹងលុបបំបាត់ពន្ធនាំចេញលើជី នីត្រូហ្សេន និងផូស្វ័រដើម្បីជំរុញភាគហ៊ុនទីផ្សាររបស់ខ្លួននៅបរទេស។ រដ្ឋមន្ត្រីពាណិជ្ជកម្មទទួលបន្ទុកកិច្ចការ RCEP បានសន្យាដាក់ចេញកិច្ចព្រមព្រៀងដែលលុបចោលពន្ធភ្លាមៗដល់កម្រិតសូន្យលើទំនិញពាណិជ្ជកម្មជាង៦៥% និងដំណាក់កាលទីពីរដែលនឹងលុបចោលពន្ធលើទំនិញដទៃទៀត។ ផលិតផលគីមីសម្រាប់កសិកម្ម ជាផ្នែកមួយនៅក្នុងនោះដែរ ហើយជាលទ្ធផលវាបង្កើនឲ្យមានសំណល់គីមីក្នុងចំណីអាហារនិងទឹក មានការបំភាយឧស្ម័នផ្ទះកញ្ចក់កាន់តែខ្លាំង និងការថយចុះជីជាតិដី។

លើសពីនេះទៅទៀត ប្រសិនបើសេចក្តីព្រាងស្តីពីកម្មសិទ្ធិបញ្ញាដែលបានបែកធ្លាយត្រូវបានអនុម័តមែននោះ RCEPអាចនឹងបង្កើនការដាក់ប៉ាតង់លើផលិតផលដទៃទៀតដូចជាឱសថព្យាបាលសត្វ ម៉ាស៊ីនធ្វើកសិកម្ម ផលិតផលធ្វើពីមីក្រូបាក់តេរីធម្មជាតិ និងផលិតផលគីមីសម្រាប់កសិកម្ម ហើយពង្រីកចិរវេលាលើប៉ាតង់របស់ខ្លួន ដែលធ្វើឲ្យផលិតផលទាំងនោះកាន់តែថ្លៃឡើងៗ។

## ៥. ការលក់រាយខ្នាតធំនឹងលុបបំបាត់ផ្សារតាមមូលដ្ឋាន

អស់រយៈពេលជាង៥ឆ្នាំនេះ តំបន់អាស៊ីប៉ាស៊ីហ្វិកជាតំបន់ដែលមានការលក់រាយ ចំណីអាហារថ្មីៗជាងពាក់កណ្តាលនៃការលក់រាយក្នុងពិភពលោក។ ប្រទេសជប៉ុនជាអ្នក ឈានមុខគេក្នុងនិន្នាការនេះ ដោយមានក្រុមហ៊ុន សេវេនអ៊ីលេវិន(7-Eleven) និង អ៊ីអន (AEON)ជាអ្នកលក់រាយចំណីអាហារធំជាងគេនៅក្នុងតំបន់។ អ៊ីអនអ៊ីគ្រិ គ្រីអេត (AEON Agri Create) ជាកម្មវិធីផលិតកម្មផ្នែកកសិកម្មរបស់ក្រុមហ៊ុនអ៊ីអន បាននឹងកំពុងបង្កើតកសិដ្ឋានក្នុងប្រទេសជប៉ុន និងប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ដូចជានៅវៀតណាម។ ក្រុមហ៊ុនអ៊ីអន ថែមទាំងមានទិសដៅជំរុញ "កសិកម្មតាមបច្ចេកវិទ្យា ICT Farming" ដែលប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាទំនាក់ទំនងក្នុងការគ្រប់គ្រងប្រតិបត្តិការនៅកសិដ្ឋាន។ នៅប្រទេសឥណ្ឌា ការបើកឲ្យមានការលក់រាយចំណីអាហារ រួមទាំងការធ្វើពាណិជ្ជកម្មតាមអេឡិចត្រូនិច ដោយមានការវិនិយោគផ្ទាល់ពីបរទេស ស្ទើរតែជិតរួចរាល់ហើយ ទោះបីជារដ្ឋភាគច្រើន មិនទាន់ត្រៀមខ្លួនក្នុងការទទួលយកការវិនិយោគផ្ទាល់ពីបរទេសក្នុងការលក់រាយនូវផលិតផលច្រើនម៉ាកក៏ដោយ។ RCEP នឹងជួយពង្រឹងនូវនិន្នាការទាំងនេះបន្ថែមទៀត។

យោងទៅតាមសេចក្តីព្រាងដែលបែកធ្លាយ ជំពូកស្តីពីសេវាកម្មនៅក្នុងRCEP អាចនឹងធ្វើឲ្យរដ្ឋាភិបាល មិនអាចដាក់កម្រិតលើប្រតិបត្តិការរបស់ខ្សែសង្វាក់ផ្សារទំនើបដែលជំរុញដោយរដ្ឋភាគីដទៃក្នុងRCEP (ការបើកទីផ្សារ)ឡើយ។ ជាងនេះទៅទៀត កិច្ចព្រមព្រៀងផ្នែកពាណិជ្ជកម្មនោះអាចចោទ រដ្ឋាភិបាលថាខុសច្បាប់ ក្នុងករណីដែលរដ្ឋាភិបាលសមាជិកមួយទាមទារឲ្យអ្នកផ្តល់សេវាកម្មណាមួយដូចជាក្រុមហ៊ុនអាលីបាបា ឬអ៊ីអន ដាក់វត្តមានប្រជាជនក្នុងស្រុកឲ្យបានចូលរួម ឬឲ្យទិញផលិតផលចំណីអាហារពីអ្នកផលិតក្នុងស្រុក។

ប្រសិនបើគម្រូដែលកំនត់នៅក្នុងTPP ត្រូវបានយកតាម នោះកសិកម្មតាមបច្ចេកវិទ្យានឹងត្រូវជំរុញក្រោមវិធានការរបស់RCEP ដែលមានទិសដៅលើកកម្ពស់សង្វាក់ផ្គត់ផ្គង់ថ្នាក់តំបន់ និងពាណិជ្ជកម្មតាមអេឡិចត្រូនិច។ ក្រុមហ៊ុនអាលីបាបារបស់ចិនទើបតែបានវិនិយោគទឹកប្រាក់ចំនួន ១,២៥ ពាន់លានដុល្លារ ទៅលើសេវាកម្មចែកចាយចំណីអាហារតាមអនឡាញដែលពឹងផ្អែកកាន់តែខ្លាំងលើឧបករណ៍បច្ចេកវិទ្យាទំនើបដែលលែងឲ្យមានចំណីអាហារតាមរដូវកាល និងផ្សារតាមមូលដ្ឋាន។ ការអភិវឌ្ឍទាំងអស់នេះ បង្កឲ្យមានការគំរាមកំហែងដ៏ពិតប្រាកដមួយទៅលើអ្នកជួញដូរ និងអ្នកលក់រាយខ្នាតតូចនៅអាស៊ី។

## តើយើងត្រូវធ្វើអ្វី?

RCEP នឹងនាំទៅរករលកមួយនៃការគ្រប់គ្រង និងក្តោបក្តាប់លើវិស័យកសិកម្ម និងចំណីអាហាររបស់អាស៊ីដោយក្រុមហ៊ុនសាជីវកម្ម។ ការក្តោបក្តាប់របស់ក្រុមហ៊ុនសាជីវកម្មដូចបទពិសោធដែលកំពុងមាននៅក្នុងតំបន់ដទៃ នឹងនាំមកនូវជម្រើសតិចតួច និងតម្លៃកាន់តែខ្ពស់សម្រាប់អ្នកប្រើប្រាស់។ នៅក្នុងវិស័យចំណីអាហារ វាក៏នាំមកនូវការចំណាយលើសុខភាព និងប៉ះពាល់ដល់បរិស្ថានដែលបង្កមកពីថ្នាំសម្លាប់សត្វល្អិត ការប្រើប្រាស់សារធាតុគីមី និងការកែច្នៃហួសកម្រិត ព្រមទាំងការបន្ទាបប្រាក់ឈ្នួល និងតម្លៃកសិផលសម្រាប់កសិករផងដែរ។

ចម្លើយទៅនឹងសំណួរនេះ គឺមិនមែនសំដៅកែទម្រង់RCEPនោះទេ ប៉ុន្តែត្រូវបដិសេធវា ពីព្រោះវាជំរុញ និងពឹងលើគម្រូកសិកម្មបែបក្រុមហ៊ុនសាជីវកម្មដែលនឹងគ្មានអ្វីកែប្រែឲ្យប្រសើរឡើយ។

ជំនួសមកវិញ ពួកយើងត្រូវអនុវត្តគោលនយោបាយ និងគំនិតផ្តួចផ្តើមណាដែលលើកទឹកចិត្តឲ្យមានប្រព័ន្ធកសិកម្មនិងចំណីអាហារដែលដឹកនាំ ដោយប្រជាជនកើតឡើង។ មានតែការធ្វើបែបនេះទេដែលអាចទាញគោលនយោបាយ ពាណិជ្ជកម្មឲ្យបម្រើប្រព័ន្ធទាំងនេះ មិនមែនឲ្យប្រព័ន្ធទាំងនេះបម្រើគោលនយោបាយ ពាណិជ្ជកម្មនោះទេ។

## ចូលរួមធ្វើសកម្មភាពពេលនេះ!

- ស្វែងរកព័ត៌មានថ្មី និងបង្កើតការពិភាក្សាដេញដោលអំពី RCEPនៅក្នុងសហគមន៍របស់អ្នក។ ប្រភពមួយដែលអ្នកអាចស្វែងរកព័ត៌មានបានគឺគេហទំព័រមួយ http://www.bilaterals.org/rcep.
- គាំទ្រសេចក្តីអំពាវនាវពីប្រជាជនឲ្យបញ្ឈប់RCEP និងប្រយុទ្ធដើម្បីប្រព័ន្ធពាណិជ្ជកម្មបម្រើប្រជាជនដែលឆ្លើយតបតម្រូវការប្រជាជន មិនមែនពួកអភិជនសាជីវកម្ម។ សូមទំនាក់ទំនងក្រុមនានាក្នុងប្រទេសរបស់អ្នកដែលបានចុះហត្ថលេខាលើសេចក្តីអំពាវនាវ និងចូលរួមជាកម្លាំង។
- ចូលរួមការប្រជុំRCEP។ សូមទាមទារឲ្យមានការបង្ហាញពីខ្លឹមសារចរចាជាសាធារណៈដើម្បីជួយដល់ការវិភាគបានប្រសើរជាងមុន និងកសាងចំនេះដឹងពីផលប៉ះពាល់នៃកិច្ចព្រមព្រៀងលើជីវភាពរស់នៅរបស់ប្រជាជននៅក្នុងប្រទេសជាសមាជិកRCEP។ សូមលើកឡើងពីក្តីកង្វល់របស់អ្នក ដូចដែលក្រុមនានាបានធ្វើនៅការប្រជុំផ្សេងៗកន្លងមកនៅទីក្រុងជើសទីក្រុងចាកាតា កូបិ និងម៉ានីល។ កិច្ចប្រជុំបន្ទាប់នឹងធ្វើនៅទីក្រុង ហ៊ីដឺរ៉ាបាត (នៅខែកក្កដាឆ្នាំ២០១៧) និងទីក្រុងសេអ៊ូល(ពេលក្រោយទៀតក្នុងឆ្នាំនេះ)។
- ចូលរួមយុទ្ធនាការប្រជាជនក្នុងទ្រង់ទ្រាយធំថ្នាក់តំបន់អំពីRCEP និងយុត្តិធម៌ក្នុងពាណិជ្ជកម្មហើយចូលរួមក្នុងការប្រមូលផ្តុំគ្នាដូចជានៅថ្ងៃធ្វើសកម្មភាពថ្នាក់តំបន់
- បន្តតាមដានតាមគេហទំព័រ http://rceplegal.wordpress.com/ និង http://keionline.org/ និង http://www/bilaterals.org/rcep-leaks ដើម្បីទទួលបានខ្លឹមសារបែកធ្លាយ និងការវិភាគផ្សេងៗពីជំពូកនៅក្នុងRCEP។